តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL Cambodia

# ការពិពណ៌នាការងារ

| | |
|---|---|
| មុខតំណែង | បុគ្គលិកហាត់ការផ្នែករដ្ឋបាល និងហិរញ្ញវត្ថុប្រចាំនៅការិយាល័យខេត្ត ចំនួន ០១រូបនៅក្នុងខេត្តនីមួយៗ(ប្រាក់ឧបត្ថម្ភប្រចាំខែ ១៥០ ដុល្លារអាមេរិច) |
| ទីកន្លែងធ្វើការ | ខេត្ត បាត់ដំបង សៀមរាប ព្រៃវែង រតនៈគិរី  កំពត និង ធ្វើដំណើរមកកាន់ រាជធានី ភ្នំពេញ និងតាមបណ្ដាខេត្តនានា |
| កម្មវិធីផ្នែក | កម្មវិធីពង្រឹងអភិបាលកិច្ច និងអភិវឌ្ឍសមត្ថភាព |
| រាយការណ៍ជូន | មន្ត្រីសម្របសម្រួលប្រចាំខេត្ត |
| ប្រភេទនៃកិច្ចសន្យា | អ្នកហាត់ការពេញម៉ោង រយៈពេល ៦ខែ (អាចបន្តបាន) |
| ថ្ងៃចាប់ផ្ដើម | ខែកក្កដា ២០១៧ |

## ១. ប្រវត្តិសង្ខេប

**អង្គការតម្លាភាពកម្ពុជា** គឺជាតំណាងប្រចាំប្រទេសរបស់អង្គការតម្លាភាពអន្តរជាតិ និងត្រូវបានបង្កើតឡើងជាផ្លូវការកាលពីថ្ងៃទី៥ ខែកក្កដាឆ្នាំ២០១០ ដោយសកម្មជនប្រឆាំងអំពើពុករលួយ និងអ្នកជំនាញដែលបានប្ដេជ្ញាចិត្តក្នុងការបង្កើតឲ្យមានតម្លាភាព និងគណនេយ្យភាពនៅកម្ពុជា។ ចាប់តាំងពីកកើតអង្គការតម្លាភាពកម្ពុជាបានក្លាយជាស្ថាប័នដែលឈានមុខគេក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ និងលើកតម្កើងសុចរិតភាព តម្លាភាព និងគណនេយ្យភាពនៅក្នុងប្រទេស។

ជាផ្នែកមួយនៃផែនការយុទ្ធសាស្ត្រ ពីបច្ចុប្បន្នរហូតដល់ឆ្នាំ ២០២០ របស់អង្គការតម្លាភាពកម្ពុជាបន្ទាប់ពីការផ្ដោតលើការលើកកម្ពស់ការយល់ដឹង គឺអង្គការតម្លាភាពកម្ពុជាផ្ដោតទៅលើសកម្មភាពជាក់លាក់ផ្នែកតម្រូវការ (អ្នកទទួលសេវា/ប្រជាពលរដ្ឋ) សំដៅចូលរួមធ្វើឲ្យកំណែទម្រង់ផ្នែកផ្គត់ផ្គង់ (អ្នកផ្ដល់សេវា)ប្រកបដោយនិរន្តរភាព។ យុទ្ធសាស្ត្រនេះ ផ្ដោតសំខាន់លើការផ្ដល់អំណាចដល់ប្រជាពលរដ្ឋ ពិសេសយុវជន ដែលជាឆ្អឹងខ្នងរបស់ប្រទេសជាតិ ហ៊ានលើកឡើងពីបញ្ហា ក្ដីកង្វល់ និងរាយការណ៍ពីអំពើពុករលួយ ដើម្បីចាត់វិធានការរួមគ្នាក្នុងការលើកកំពស់តម្លាភាព សុចរិតភាព អភិបាលកិច្ចល្អ ទំនួលខុសត្រូវសង្គម និងការប្រឆាំងអំពើពុករលួយ។

## ២. គោលដៅរួម

ផ្ដល់ការគាំទ្រ ជាពិសេសផ្នែករដ្ឋបាល និងហិរញ្ញវត្ថុនៅថ្នាក់ខេត្តរបស់អង្គការតម្លាភាពកម្ពុជាក្នុងការកសាងយុទ្ធសាស្ត្រលើកកម្ពស់សុចរិតភាព តម្លាភាព និងការប្រឆាំងអំពើពុករលួយនៅថ្នាក់ក្រោមជាតិ។

## ៣. គោលបំណង

- ផ្ដល់ការគាំទ្រដល់ការបង្កើតការិយាល័យថ្នាក់តំបន់ និងប្រតិបត្តិការកម្មវិធី និងកិច្ចការរដ្ឋបាលប្រចាំថ្ងៃរបស់ការិយាល័យថ្នាក់ខេត្ត (ការគ្រប់គ្រងការិយាល័យ និងហិរញ្ញវត្ថុ)

- ធានាដំណើរការ ការិយាល័យថ្នាក់តំខេត្ត ស្របតាមគោលការណ៍ និងគោលនយោបាយរបស់អង្គការតម្លាភាពកម្ពុជា ក៏ដូចជាម្ចាស់ជំនួយ។
- ធានា តម្លាភាព សុចរិតភាព ប្រសិទ្ធិភាព ប្រសិទ្ធិផល នៅការិយាល័យថ្នាក់តំបន់។

## ៤. ទំនួលខុសត្រូវរួម

### ក. ផ្នែករដ្ឋបាល

- ជួយមន្ត្រីសម្របសម្រួលថ្នាក់ខេត្ត ក្នុងការជ្រើសរើសបុគ្គលិក អ្នកហាត់ការ និងអ្នកស្ម័គ្រចិត្ត នៅក្នុងខេត្ត
- ចាត់ចែងសម្ភារៈការិយាល័យ ឧបករណ៍ និងសម្ភារៈប្រើប្រាស់ផ្សេងៗក្នុងការិយាល័យ និងកត់ត្រាអោយបានត្រឹមត្រូវជាប្រចាំ
- ជួយអ្នកសម្របសម្រួលថ្នាក់ខេត្តដើម្បីធានាការអនុវត្តគម្រោងក៏ដូចជាការចំណាយផ្សេងៗស្របតាគោលការណ៍ និងគោលនយោបាយរបស់អង្គការតម្លាភាពកម្ពុជា ក៏ដូចជាម្ចាស់ជំនួយនៅថ្នាក់ក្រោមជាតិប្រកបដោយប្រសិទ្ធិភាព និងប្រសិទ្ធិផល
- រក្សាទុកឯកសារជាអេឡិចត្រូនិក និងឯកសារថតចម្លងអោយបានត្រឹមត្រូវ
- រៀបចំកិច្ចប្រជុំផ្សេងៗ
- ផ្តល់កិច្ចគាំទ្រគ្រប់ជំហ៊ានពាក់ព័ន្ធនឹងកិច្ចការធនធានមនុស្ស

### ខ.ផ្នែកហិរញ្ញវត្ថុ

- ដោះស្រាយ ធានា និងកត់ត្រាចំណាយក្នុងបញ្ជីកត់ត្រាប្រចាំថ្ងៃ
- ធានាការទូទាត់ចំណាយ និងការចំណាយពាក់ព័ន្ធផ្សេងៗឲ្យទាន់ពេលវេលា
- រៀបចំបញ្ជីចំណាយតិចតួច និងធ្វើបច្ចុប្បន្នភាពរាល់ថ្ងៃដើម្បីធានាថាមានសាច់ប្រាក់សម្រាប់ចំណាយ
- រៀបចំការចំណាយប្រាក់តាមការស្នើសុំ
- រក្សា និងធ្វើបច្ចុប្បន្នភាពជាប្រចាំលើបញ្ជីសារពើភ័ណ្ឌរបស់អង្គការតម្លាភាពនៅការិយាល័យថ្នាក់ខេត្ត
- ធ្វើការងារផ្សេងៗដែលតម្រូវដោយអ្នកសម្របសម្រួលកម្មវិធី

## ៥. លក្ខណៈសម្បត្តិរបស់បេក្ខជន៖

- កំពុងសិក្សាឬ បញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាញពាក់ព័ន្ធ
- អតីត ឬបច្ចុប្បន្នជាសមាជិកប្រជាពលរដ្ឋ/ក្រុមយុវជន របស់អង្គការតម្លាភាពកម្ពុជា ដូចជាអ្នកហាត់ការងារ អ្នកស្ម័គ្រចិត្ត និងអ្នកដែលបាននិងកំពុងចូលរួមកម្មវិធីភាពជាអ្នកដឹកនាំវ័យក្មេង កម្មវិធីបោះជំរំស្តីពីការផ្តល់អំណាចដល់យុវជនដើម្បីតម្លាភាព និងសុចរិតភាព និងគំនិតផ្តួចផ្តើមដឹកនាំដោយយុវជនត្រូវបានលើកទឹកចិត្តជាពិសេស
- ជាប្រជាពលរដ្ឋអចិន្ត្រៃយ៍ និងកំពុងកំពុងរស់នៅខេត្តគោលដៅនីមួយៗ
- មានបទពិសោធន៍ខ្លះៗក្នុងការគ្រប់គ្រងសកម្មភាពគម្រោង និងហិរញ្ញវត្ថុ
- មានបទពិសោធន៍ក្នុងការអនុវត្តន៍គម្រោងសហគមន៍

- មានជំនាញទំនាក់ទំនងនិងជំនាញអន្តរបុគ្គលយ៉ាងស្ទាត់ជំនាញ និងអាចលើកស្ទួយទំនាក់ទំនង ប្រកបដោយវិជ្ជាជីវៈជាមួយគ្រប់ភាគីពាក់ព័ន្ធ ជាពិសេសជាមួយអង្គាធរមូលដ្ឋាន
- អាចធ្វើការក្រោមសម្ពាធការងារ ការយកចិត្តទុកដាក់ និងប្រឹងប្រែងធ្វើការងារ
- ប្តេជ្ញាប្រកាន់យកគុណតម្លៃរបស់អង្គការតម្លាភាពកម្ពុជា
- អ្នកអាចនិយាយ និងសរសេរភាសាអង់គ្លេសបានត្រូវបានលើកទឹកចិត្ត